ADB

ASIAN DEVELOPMENT BANK
6 ADB Avenue, Mandaluyong City
1550 Metro Manila, Philippines
Tel + 63 2 632 4444
Fax + 63 2 636 4444

www.adb.org

NEWS RELEASE

# ធនាគារអភិវឌ្ឍន៍អាស៊ី ប្រកាសជ័យលាភីការប្រកួតរូបថតតាម Instagram ដើម្បីអបអរសាទរខួប ២៥ ឆ្នាំ នៃកម្មវិធីមហាអនុតំបន់ទន្លេមេគង្គ (GMS)

ទីក្រុងម៉ានីល ប្រទេសហ្វីលីពីន (ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៨) — ថ្ងៃនេះ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធ្វើការប្រកាសជ័យលាភីនៃការប្រកួតប្រជែងរូបថតតាម Instagram របស់ខ្លួន ដែលត្រូវបានរៀបចំឡើង សំដៅបង្ហាញពីវឌ្ឍនភាពនៃការអភិវឌ្ឍ ដែលសម្រេចបាន ក្នុងមហាអនុតំបន់ទន្លេមេគង្គ ដើម្បីអបអរសាទរខួបទី ២៥ នៃកម្មវិធីមហាអនុតំបន់ទន្លេមេគង្គ (GMS)។

លោក Anh Dũng Kiều មកពីប្រទេសវៀតណាម ឈ្នះជ័យលាភីទី ១ ដោយទទួលបានទឹកប្រាក់ ៥០០ ដុល្លារសម្រាប់រូបថត ដែលបង្ហាញពីសកម្មភាពលក់ដូរនៅព្រឹកព្រហាមក្នុងទីផ្សារបណ្តែតទឹក Soc Trang។ លោក P. Pitchayawat មកពីប្រទេសថៃ ឈ្នះជ័យលាភីទី ២ ជាមួយនឹងរង្វាន់ជាសាច់ប្រាក់ចំនួន ២០០ ដុល្លារ ខណៈពេលដែល លោក Saravut Whanset មកពីប្រទេសថៃដែរ ឈ្នះរង្វាន់ពិសេស ដោយទទួលបានទឹកប្រាក់ ១០០ ដុល្លារ សម្រាប់រូបថត ដែលទទួលបានការចូលចិត្ត (Like) ច្រើនជាងគេ។

ការប្រកួតប្រជែងរូបថត ដែលដំណើរការចាប់ពីថ្ងៃទី ៨ ខែ មករា រហូតដល់ថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១៨ នេះ បានទទួលរូបថតជាង ១.២០០ សន្លឹក ពីអ្នកថតរូបមិនមែនអាជីព មកពីប្រទេសជាសមាជិករបស់ ADB។ ដោយប្រើ hashtag #GMS25 រូបថតទាំងនេះ បង្ហាញពីការប្រែប្រួលនៃជីវិតរស់នៅប្រចាំថ្ងៃក្នុងមហាអនុតំបន់ទន្លេមេគង្គ ក្នុងរយៈពេល ២៥ ឆ្នាំចុងក្រោយនេះ។ ជ័យលាភីនឹងត្រូវទាក់ទងដោយតំណាងរបស់ ADB ដើម្បីពន្យល់ពីរបៀបបើកប្រាក់រង្វាន់របស់ពួកគេ។

ប្រទេសចូលរួមក្នុងកម្មវិធី GMS ដែលជាកម្មវិធីផ្តោតលើការបង្កើនកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មថ្នាក់តំបន់ ដើម្បីការអភិវឌ្ឍបរិយាប័ន្ន និងចីរភាព រួមមាន ប្រទេសកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន (ជាពិសេសខេត្ត Yunnan និងតំបន់ស្វយ័ត Guangxi Zhuang) ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម។

**Media Inquiries**

Jane Zhang
Tel. (632) 632 5105
Mob: (63) 999 999 5105
Email: janezhang@adb.org

Connect with us on social media:

AsianDevBank
@ADB_HQ
@ADB_HQ
Asian-Development-Bank

បង្កើតឡើងក្នុងឆ្នាំ ១៩៩២ ដែលមានការគាំទ្រពី ADB កម្មវិធី GMS នេះ បានជួយអនុវត្តគម្រោងជាអាទិភាពក្នុងអនុតំបន់នេះ ដោយផ្តោតលើវិស័យគមនាគមន៍ ថាមពល ទូរគមនាគមន៍ បរិស្ថាន ការអភិវឌ្ឍធនធានមនុស្ស ទេសចរណ៍ ពាណិជ្ជកម្ម ការវិនិយោគវិស័យឯកជន និងកសិកម្ម។ គិតត្រឹមឆ្នាំ ២០១៧ ADB បានអនុម័តលើឥណទាន និងហិរញ្ញប្បទានឥតសំណងចំនួន ៨៧ គម្រោងក្នុងទឹកប្រាក់ ៨,២ ពាន់លានដុល្លារ ខណៈពេលដែលប្រទេសជាសមាជិកនៅកម្មវិធី GMS រួមភាគទានចំនួន ៥,៥ ពាន់លានដុល្លារ ហើយដៃគូអភិវឌ្ឍន៍បានផ្តល់ ៧,១ ពាន់លានដុល្លារ។

កិច្ចប្រជុំកំពូលលើកទី ៦ នៃកម្មវិធីមហាអនុតំបន់ទន្លេមេគង្គ ក្រោមប្រធានបទ *ទាញប្រយោជន៍ពីកិច្ចសហប្រតិបត្តិការរយៈពេល ២៥ ឆ្នាំ និងការកសាងមហាអនុតំបន់ទន្លេមេគង្គ ប្រកបដោយចីរភាព សមាហរណកម្ម និងវិបុលភាព* នឹងត្រូវរៀបចំឡើងពីថ្ងៃទី ២៩ ដល់ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៨។ ថ្នាក់ដឹកនាំនៃបណ្តាប្រទេសមហាអនុតំបន់ទន្លេមេគង្គនឹងចូលរួមក្នុងព្រឹត្តិការណ៍នេះ ព្រមទាំងអនុម័តលើផែនការសកម្មភាពទីក្រុងហាណូយ ២០១៨-២០២២។ អ្នកដែលនឹងត្រូវចូលរួមក្នុងកិច្ចប្រជុំកំពូលនេះផងដែរ រួមមាន មន្ត្រីសាធារណៈជាន់ខ្ពស់ផ្សេងៗទៀត តំណាងវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ដូចជា ADB និងអ្នកសារព័ត៌មានជាដើម។

មានមូលដ្ឋាននៅទីក្រុងម៉ានីល ADB ប្តេជ្ញាកាត់បន្ថយភាពក្រីក្រនៅតំបន់អាស៊ីប៉ាស៊ីហ្វិក តាមរយៈកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន កំណើនដែលធានានិរន្តរភាពបរិស្ថាន និងសមាហរណកម្មថ្នាក់តំបន់។ បង្កើតឡើងក្នុងឆ្នាំ ១៩៦៦ ធនាគារនេះជាកម្មសិទ្ធិរបស់ប្រទេសចំនួន ៦៧ ដែលក្នុងនោះ ៤៨ ប្រទេស មកពីតំបន់នេះ។